**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២១ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (ONLINE SCAMS)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (ONLINE SCAMS) ដែលសរសេរជាអក្សរកាត់ថា **គ.ប.ឆ.ប.** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** | នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២-ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម **ប្រាក់ សុខុន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

៤-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៥-ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធាន

៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អនុប្រធាន

៧-ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អនុប្រធាន

៨-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី អនុប្រធាន

៩-ឯកឧត្តមសន្តិបណ្ឌិត **ឆៃ ស៊ីណារិទ្ធ** ទេសរដ្ឋមន្ត្រី អនុប្រធានប្រចាំការ

១០-ឯកឧត្តម **កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល សមាជិក

១១-ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន សមាជិក

១២-ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

១៣-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី** រដ្ឋលេខាធិការប្រចាំការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **វង្ស ពិសេន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

១៥-ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនគរបាលជាតិ សមាជិក

១៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ សុផាន់** អគ្គមេបញ្ជាការរង
និងជាមេបញ្ជាការកងទ័ពជើងគោក សមាជិក

១៧-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរង និងជា
មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៨-ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ វាសនា** អគ្គនាយក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ សមាជិក

១៩-ឯកឧត្តមឧត្តមសេនីយ៍ឯក **តុប នេត** អគ្គនាយក អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក

២០-ឯកឧត្តមឧត្តមសេនីយ៍ឯក **ឌី វិជ្ជា** អគ្គស្នងការរងនគរបាលជាតិ សមាជិក

២១-ឯកឧត្តម **រស់ តីរុណា** អគ្គលេខាធិការគណៈកម្មការគ្រប់គ្រង
ល្បែងពាណិជ្ជកម្មកម្ពុជា សមាជិក

២២-ឧត្តមសេនីយ៍ឯក **ហែម ថា** មេបញ្ជាការកងពលតូចលេខ៧០ កងទ័ពជើងគោក សមាជិក

២៣-ឧត្តមសេនីយ៍ទោ **សំ ឥស្ស** មេបញ្ជាការ បញ្ជាការដ្ឋានជាតិកម្លាំងពិសេស
ប្រឆាំងភេរវកម្ម សមាជិក

២៤-ឧត្តមសេនីយ៍ទោ **ស៊ុំ សំណាង** មេបញ្ជាការ បញ្ជាការដ្ឋានទ័ពពិសេស
កងទ័ពជើងគោក សមាជិក

២៥-ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក។

**ប្រការ២ ._**

**គ.ប.ឆ.ប**. មានភារកិច្ចដូចតទៅ៖

- ដាក់ចេញវិធានការក្នុងការបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ( ONLINE SCAMS )
- ដាក់ចេញវិធានការក្នុងការបង្ការនិងទប់ស្កាត់ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា
- ផ្តល់ការណែនាំ សម្របសម្រួល គាំទ្រ និងអន្តរាគមន៍ចាំបាច់នានា ដើម្បីជំរុញការអនុវត្តរបស់ក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាឱ្យមានប្រសិទ្ធភាពខ្ពស់

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់ក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា
- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេសពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

**ប្រការ៣ .-**

អនុប្រធាន និងសមាជិកនៃ **គ.ប.ឆ.ប.** ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន **គ.ប.ឆ.ប.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ប.ឆ.ប.** អាចប្រគល់សិទ្ធិជូនអនុប្រធានកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំជំនួសបាន។

**គ.ប.ឆ.ប.** អញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៤ .-**

**គ.ប.ឆ.ប.** មានសិទ្ធិប្រើប្រាស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងមន្ត្រីអនុវត្តច្បាប់ពីបណ្តាក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការបំពេញប្រតិបត្តិការបង្ក្រាបនិងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

ក្នុងករណីចាំបាច់ តាមរយៈការប្រគល់សិទ្ធិរបស់ប្រធាន **គ.ប.ឆ.ប.** ប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.** សហការ និងសម្របសម្រួលជាមួយនឹងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងមន្ត្រីអនុវត្តច្បាប់ពីបណ្តាក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការបំពេញប្រតិបត្តិការបង្ក្រាបនិងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

**ប្រការ៥ .-**

**គ.ប.ឆ.ប.** ប្រើត្រារបស់គណៈរដ្ឋមន្ត្រីសម្រាប់ដំណើរការការងារ។

**គ.ប.ឆ.ប.** មានកញ្ចប់ថវិកាពិសេសរបស់រាជរដ្ឋាភិបាលសម្រាប់ដំណើរការការងារ។

**ប្រការ៦ .-**

លេខាធិការដ្ឋាន **គ.ប.ឆ.ប.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តមសន្តិបណ្ឌិត **នៃ ស៊ីណារិទ្ធ** | ទេសរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តមនាយឧត្តមសេនីយ៍ **ជួន សុវណ្ណ** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម **ប្រាក់ សំរឿន** | នាយករងខុទ្ទកាល័យ<br>សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** | អនុប្រធាន |
| ៤-ឯកឧត្តមឧត្តមសេនីយ៍ឯក **ឌី ពិជ្ជា** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធាន |
| ៥-ឯកឧត្តម **ម៉ុក ច័ន្ទសុធា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៦-ឯកឧត្តម **អេន សុខឿន** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៧-ឯកឧត្តម **សង់ ស៊ីណាម៉ុន** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៨-ឯកឧត្តម **ម៉ិន ហុន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៩-ឯកឧត្តម **កែវ សុម៉ារិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ១០-ឯកឧត្តម **ឆេង អស្តារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |

| | | |
|---|---|---|
| ១១-លោកជំទាវ **យិនឡៀង ពុទ្ធិរស្មី** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ១២-ឯកឧត្តមឧត្តមសេនីយ៍ទោ **លូ រ៉ាមុ** | អគ្គនាយករង អគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១៣-ឯកឧត្តម **គឹម ចន្ទ្បានសោភ័ណ** | អគ្គនាយករង អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ១៤-ឯកឧត្តម **ឌុច ឧត្តម** | អគ្គនាយករង អគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច | សមាជិក |
| ១៥-ឯកឧត្តម **យិនឡៀង ពុទ្ធីរិទ្ធ** | សមាជិកលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម | សមាជិក |
| ១៦-ឯកឧត្តម **ស្រ៊ុន គឹមសាន** | សមាជិកនិយ័តករទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១៧-ឯកឧត្តម **ហេង ស៊ីឡើន** | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៨-លោក **ឆឹម រ៉ាឌុឡ** | នាយកអាជីវកម្មចែកចាយ អគ្គិសនីកម្ពុជា | សមាជិក។ |

**ប្រការ៧ .-**

លេខាធិការដ្ឋាន **គ.ប.ឆ.ប.** មានតួនាទីជាសេនាធិការឱ្យ **គ.ប.ឆ.ប.** និងមានភារកិច្ចដូចខាងក្រោម៖

- កសាងផែនការស្រាវជ្រាវ ប្រមូលព័ត៌មាន ផែនការសកម្មភាពសម្រាប់បម្រើឱ្យវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីស្នើសុំការសម្រេចពី **គ.ប.ឆ.ប.**
- ប្រមូលភស្តុតាងនិងកំណត់មុខសញ្ញាសង្ស័យ ដោយអនុវត្តតាមនីតិវិធីច្បាប់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការដែលបានដាក់ចេញដោយ **គ.ប.ឆ.ប.**
- អន្តរាគមន៍ចាំបាច់នានា ដើម្បីជំរុញការអនុវត្តវិធានការដែលបានដាក់ចេញដោយ **គ.ប.ឆ.ប.**
- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេសពាក់ព័ន្ធ
- សហការ សម្របសម្រួល និងជំរុញក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការបំពេញប្រតិបត្តិការបង្ក្រាបនិងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា
- ដឹកនាំបញ្ជាអង្គភាពអន្តរាគមន៍ពិសេសក្នុងការបំពេញប្រតិបត្តិការនានា បន្ទាប់ពីទទួលបានគោលការណ៍ឯកភាពពីប្រធាន **គ.ប.ឆ.ប.**
- រៀបចំកិច្ចប្រជុំនានារបស់ **គ.ប.ឆ.ប.** តាមការណែនាំរបស់ប្រធាន **គ.ប.ឆ.ប.**
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូន **គ.ប.ឆ.ប.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ប.ឆ.ប.**។

**ប្រការ៨ .-**

លេខាធិការដ្ឋាន **គ.ប.ឆ.ប.** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ដំណើរការការងារ។

**ប្រការ៩ .-**

លេខាធិការដ្ឋាន **គ.ប.ឆ.ប.** លើកសំណើថវិកា មធ្យោបាយ សម្ភារ ឧបករណ៍បច្ចេកទេស និងទីតាំងសម្រាប់បម្រើការងារនិងប្រតិបត្តិការជូនប្រធាន **គ.ប.ឆ.ប.** ពិនិត្យនិងសម្រេច។

**ប្រការ១០ .-**

លេខាធិការដ្ឋាន **គ.ប.ឆ.ប.** មានមន្ត្រីនិងកងកម្លាំងប្រដាប់អាវុធក្របខ័ណ្ឌនៃក្រសួង ស្ថាប័ន និងអង្គភាពដែលមកបម្រើការងារប្រចាំថ្ងៃតាមតម្រូវការជាក់ស្តែង។ មន្ត្រីនិងកងកម្លាំងប្រដាប់អាវុធក្របខ័ណ្ឌនៃក្រសួង ស្ថាប័ន

និងអង្គភាពដែលមកបម្រើការងារក្នុងលេខាធិការដ្ឋាន **គ.ប.ឆ.ប.** ត្រូវចាត់តាំងដោយលិខិតបង្គាប់ការរបស់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នឬអង្គភាព តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.** បន្ទាប់ពីទទួលបានការឯកភាពពីប្រធាន **គ.ប.ឆ.ប.**។

ក្នុងករណីចាំបាច់ លេខាធិការដ្ឋាន **គ.ប.ឆ.ប.** អាចជ្រើសរើសបុគ្គលិកដែលមិនមែនជាមន្ត្រីក្របខ័ណ្ឌមកបម្រើការងារក្នុងលេខាធិការដ្ឋាន **គ.ប.ឆ.ប.** ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១១ .-**

មន្ត្រីនិងកងកម្លាំងប្រដាប់អាវុធក្របខ័ណ្ឌនៃក្រសួង ស្ថាប័ន និងអង្គភាពនានា ដែលត្រូវបានចាត់តាំងឱ្យមកបម្រើការងារក្នុងលេខាធិការដ្ឋាន **គ.ប.ឆ.ប.** ត្រូវបានរក្សានូវមុខតំណែង អតីតភាពការងារ និងការដំឡើងឋានន្តរស័ក្តិ ថ្នាក់ បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់ខ្លួននៅក្រសួង ស្ថាប័ន និងអង្គភាពដើម ហើយពុំចាំបាច់ដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬផ្ទេរក្របខ័ណ្ឌឡើយ។

មន្ត្រីនិងកងកម្លាំងប្រដាប់អាវុធក្របខ័ណ្ឌនៃក្រសួង ស្ថាប័ន និងអង្គភាពនានា ត្រូវត្រឡប់ទៅបំពេញការងារតាមតួនាទីនៅតាមក្រសួង ស្ថាប័ន និងអង្គភាពដើមរបស់ខ្លួនវិញ នៅពេលបញ្ចប់ភារកិច្ចក្នុងលេខាធិការដ្ឋាន **គ.ប.ឆ.ប.**។

**ប្រការ១២ .-**

លេខាធិការដ្ឋាន **គ.ប.ឆ.ប.** មានក្រុមការងារចំណុះ ចំនួន ៦ និងអង្គភាពអន្តរាគមន៍ពិសេស ចំនួន ១ ដូចខាងក្រោម៖

១- ក្រុមការងារស្រាវជ្រាវនិងស៊ើបអង្កេត

២- ក្រុមការងារបច្ចេកវិទ្យាព័ត៌មាន

៣- ក្រុមការងារប្រតិបត្តិការនិងនីតិវិធី

៤- ក្រុមការងារទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ

៥- ក្រុមការងារផ្សព្វផ្សាយនិងសាធារណមតិ

៦- ក្រុមការងារកិច្ចការទូទៅ

៧- អង្គភាពអន្តរាគមន៍ពិសេស។

**ប្រការ១៣ .-**

ក្រុមការងារស្រាវជ្រាវនិងស៊ើបអង្កេត មានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ ប្រមូល និងវិភាគព័ត៌មានដែលទទួលបានពីគ្រប់មជ្ឈដ្ឋានក្នុងនិងក្រៅប្រទេស
- ស៊ើបអង្កេត តាមដានមុខសញ្ញាសង្ស័យ និងប្រមូលភស្តុតាងដើម្បីបើកសំណុំរឿង ដោយអនុលោមតាមនីតិវិធីច្បាប់
- ធ្វើរបាយការណ៍រាយការណ៍ជូនប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**។

**ប្រការ១៤ .-**

ក្រុមការងារបច្ចេកវិទ្យាព័ត៌មាន មានភារកិច្ចដូចខាងក្រោម៖

- សហការស្រាវជ្រាវតាមប្រព័ន្ធបច្ចេកវិទ្យា
- ស៊ើបអង្កេតនិងធ្វើកោសល្យវិច័យលើឧបករណ៍អេឡិចត្រូនិករបស់មុខសញ្ញាសង្ស័យដែលបានប្រើប្រាស់

- រក្សាទុកទិន្នន័យនិងកស្តុតាង
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពដែលទទួលកិច្ចការងារបច្ចេកវិទ្យានិងបណ្តាប្រតិបត្តិករទូរគមនាគមន៍គ្រប់ប្រភេទ
- ធ្វើរបាយការណ៍រាយការណ៍ជូនប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**។

**ប្រការ១៥ .-**

ក្រុមការងារប្រតិបត្តិការនិងនីតិវិធី មានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយស្ថាប័ននិងអង្គភាពអនុវត្តច្បាប់ដែលពាក់ព័ន្ធក្នុងការកសាងសំណុំរឿង ដើម្បីបញ្ជូនទៅអយ្យការអមសាលាដំបូង
- គ្រប់គ្រង ស្រាវជ្រាវ និងស្តាប់ចម្លើយមុខសញ្ញាសង្ស័យ ដោយអនុលោមតាមនីតិវិធីច្បាប់
- សហការនិងតាមដានការអនុវត្តដីការបស់អាជ្ញាធរតុលាការ
- ធ្វើរបាយការណ៍រាយការណ៍ជូនប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**។

**ប្រការ១៦ .-**

ក្រុមការងារទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេសពាក់ព័ន្ធ
- សហការសម្របសម្រួលដើម្បីកំណត់មុខសញ្ញាសង្ស័យ
- ផ្លាស់ប្តូរព័ត៌មាននិងស៊ើបបញ្ជាក់មុខសញ្ញាសង្ស័យពាក់ព័ន្ធនៅក្រៅប្រទេស
- សហការជាមួយស្ថាប័នពាក់ព័ន្ធនិងស្ថានទូតលើកិច្ចការដែលពាក់ព័ន្ធជាមួយជនបរទេស
- ធ្វើរបាយការណ៍រាយការណ៍ជូនប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**។

**ប្រការ១៧ .-**

ក្រុមការងារផ្សព្វផ្សាយនិងសាធារណមតិ មានភារកិច្ចដូចខាងក្រោម៖

- តាមដាននិងប្រមូលព័ត៌មានទាំងក្នុងនិងក្រៅប្រទេសដែលបានផ្សព្វផ្សាយពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា
- ចងក្រងឯកសារអំពីការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីរៀបចំជាការផ្សព្វផ្សាយ អប់រំ និងបញ្ជ្រាបការយល់ដឹងដល់សាធារណជន
- ប្រតិកម្មនិងឆ្លើយតបជុំវិញព័ត៌មានដែលពាក់ព័ន្ធការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា
- ធ្វើរបាយការណ៍រាយការណ៍ជូនប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**។

**ប្រការ១៨ .-**

ក្រុមការងារកិច្ចការទូទៅ មានភារកិច្ចដូចខាងក្រោម៖

- កសាងផែនការសកម្មភាពរបស់លេខាធិការដ្ឋាន **គ.ប.ឆ.ប.**
- ត្រួតពិនិត្យការអនុវត្តការងារនិងចាត់ចែងថវិកា មធ្យោបាយ សម្ភារ និងឧបករណ៍បច្ចេកទេស

- ចាត់ចែងការងារពិធីការនិងរៀបចំកិច្ចប្រជុំនានារបស់លេខាធិការដ្ឋាន និង **គ.ប.ឆ.ប.**
- ធ្វើរបាយការណ៍គ្រប់កិច្ចប្រជុំរបស់លេខាធិការដ្ឋាន និង **គ.ប.ឆ.ប.**
- ប្រមូលរបាយការណ៍បូកសរុបការងារប្រចាំថ្ងៃ សប្តាហ៍ ខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍រាយការណ៍ជូនប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ប.ឆ.ប.**។

**ប្រការ១៩ .-**

**គ.ប.ឆ.ប.** មានអង្គភាពអន្តរាគមន៍ពិសេស ដើម្បីគាំទ្រដល់ការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលដឹកនាំបញ្ជាផ្ទាល់ដោយប្រធាន **គ.ប.ឆ.ប.**។

ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងតួនាទីនិងភារកិច្ចរបស់អង្គភាពអន្តរាគមន៍ពិសេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី។

**ប្រការ២០ .-**

លេខាធិការដ្ឋាន **គ.ប.ឆ.ប.** អាចមានក្រុមការងារចាំបាច់ផ្សេងទៀត តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

ការតែងតាំង បំពេញបន្ថែម និងផ្លាស់ប្តូរសមាសភាពនៃលេខាធិការដ្ឋាន **គ.ប.ឆ.ប.** ក្រុមការងារចំណុះ និងអង្គភាពអន្តរាគមន៍ពិសេសរបស់លេខាធិការដ្ឋាន **គ.ប.ឆ.ប.** ត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី។

**ប្រការ២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ